Phnom Penh, August 6, 2019

# PRESS ANNOUNCEMENT

## Training for health workers on Maternal and Child Health Educational Handbook

Svay Rieng Provincial Health Department and JICA's Project for Improving Continuum of Care with focus on Intrapartum and Neonatal Care in Cambodia (IINeoC Project) will organize the training for health workers on "Maternal and Child Health Educational Handbook" on 8 and 9 August, 2019 from 8:00AM at a meeting room of Svay Rieng Provincial Health Department. Around 60 midwives from Health Centers of Svay Rieng Province are expected to join this training.

JICA IINeoC Project has developed a Cambodian version of the Mother and Child Health Educational Handbook (Booklet) with the National Maternal and Child Health Center based on some national guidelines and WHO recommendations. This booklet has been distributed with these existing national records (Pink card and Yellow card*) as a comprehensive package in one card holder at selected health centers of Svay Rieng Province since February 2019, as a pilot. These health centers have introduced the booklet into their routine Antenatal Care services. Along with the expanding of distribution to the other Operational District (Romeas Heak OD) from August 2019, JICA IINeoC project and Svay Rieng Provincial Health Department will hold the training.

The purpose of this training is to improve health worker's knowledge and enhance health educational skill using the booklet. Through this booklet, we hope pregnant mothers have essential knowledge for improvement of maternal and child health.

In this occasion, JICA IINeoC project and Svay Rieng Provincial Health Department would like to invite journalists from both public and private media sectors to write a news report about this training.

For more information, please contact Ms. Yoko Masaki, JICA's expert on maternal and newborn community health, IINeoC project via mobile phone: 012 222 941 or email: yoko.masaki314@gmail.com, or Ms. Ros Sopheasavetey, Technical Assistant, via Office Phone: 078 769 107 or Email: iineoc.ta.kcm@gmail.com.

*Pink card: Record Card for Antenatal Care, Delivery and Postnatal Care.

** Yellow card: Record Card for immunization and Growth Monitoring Chart.

ភ្នំពេញ, ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩

# សេចក្ដីប្រកាសព័ត៌មាន

## វគ្គបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកសុខាភិបាលអំពីសៀវភៅអប់រំសុខភាពមាតា និងទារក

មន្ទីរសុខាភិបាលខេត្តស្វាយរៀង និងគម្រោងលើកកម្ពស់ការថែទាំបន្តនៅកម្ពុជាផ្ដោតលើការថែទាំស្ត្រី និងទារកក្នុងពេលសម្រាលនិងក្រោយពេលសម្រាល (ហៅកាត់ គម្រោង IINeoC) របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) នឹងរៀបចំវគ្គបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកសុខាភិបាលអំពី "សៀវភៅអប់រំសុខភាពមាតានិងទារក" នៅថ្ងៃទី៨ និងទី៩ ខែសីហា ឆ្នាំ២០១៩ ចាប់ពីម៉ោង ៨:០០ព្រឹក នៅសាលប្រជុំនៃមន្ទីសុខាភិបាលខេត្តស្វាយរៀងដែលមានឆ្មបប្រមាណ ៦០នាក់មកពីមណ្ឌលសុខភាពនឹងចូលរួមវគ្គបណ្ដុះបណ្ដាលនេះ។

គម្រោង IINeoC និងមជ្ឈមណ្ឌលជាតិសុខភាពមាតានិងទារក បានបង្កើតសៀវភៅអប់រំសុខភាពមាតានិងទារក (កូនសៀវភៅអប់រំសុខភាព) ដោយផ្អែកទៅលើគោលការណ៍ណែនាំថ្នាក់ជាតិ និងអនុសាសន៍របស់អង្គការសុខភាពពិភពលោក។ កូនសៀវភៅអប់រំសុខភាពនេះ ត្រូវបានចែកចាយភ្ជាប់ជាមួយនឹងកំណត់ត្រាជាតិដែលមានស្រាប់ (កូនសៀវភៅពណ៌ផ្កាឈូក និងប័ណ្ណពណ៌លឿង) នៅតាមមណ្ឌលសុខភាពគោលដៅក្នុងខេត្តស្វាយរៀង តាំងពីខែកុម្ភៈ ឆ្នាំ២០១៩ ដែលជាដំណាក់កាលសាកល្បង។ មណ្ឌលសុខភាពទាំងនោះ បានណែនាំកូនសៀវភៅអប់រំសុខភាពនេះដល់ស្ត្រីដែលមកទទួលសេវាពិនិត្យផ្ទៃពោះជាប្រចាំ។ ដោយមានការពង្រីកការចែកចាយកូនសៀវភៅអប់រំសុខភាពនេះទៅដល់ស្រុកប្រតិបត្តិ (ស្រុកប្រតិបត្តិរមាសហែក) នាខែសីហា ឆ្នាំ២០១៩ កន្លងមក គម្រោង IINeoC និងមន្ទី សុខាភិបាលខេត្តស្វាយរៀងនឹងរៀបចំការបណ្ដុះបណ្ដាលខាងលើនេះ។
វគ្គបណ្ដុះបណ្ដាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងបុគ្គលិកសុខាភិបាល និងពង្រីកន្ថែមនូវជំនាញអប់រំសុខភាពតាមរយៈការប្រើប្រាស់កូនសៀវភៅអប់រំសុខភាពនេះ។
យើងសង្ឃឹមថា ស្ត្រីមានផ្ទៃពោះនឹងមានចំណេះដឹងចាំបាច់អំពីសុខភាពមាតានិងទារក។

នាឱកាសនេះ គម្រោង IINeoC និងមន្ទីរពេទ្យសុខាភិបាលស្វាយរៀង សូមគោរពអញ្ជើញអ្នកសារពត៌មានរដ្ឋនិងឯកជនទាំងអស់មេត្តាចូលរួមវគ្គបណ្ដុះបណ្ដាលនេះដោយក្ដីអនុគ្រោះ។

<u>សម្រាប់ពត៌មានបន្ថែម</u> សូមទំនាក់ទំនងលោកស្រី **យ៉ូកូ ម៉ាសាគី** ជំនាញការផ្នែកសុខភាពសហគមន៍មាតានិងទារករបស់គម្រោង IINeoC តាមលេខរយៈទូរស័ព្ទ 012 222 941 ឬអ៊ីម៉ែល yoko.masaki314@gmail.com ឬកញ្ញា **រស់ សុភាសាវតី** ជំនួយការបច្ចេកទេស តាមរយៈលេខទូរស័ព្ទការិយាល័យ: 078 769 107 ឬ អ៊ីម៉ែល iineoc.ta.kcm@gmail.com។

*កូនសៀវភៅពណ៌ផ្កាឈូក: សៀវភៅសុខភាពមាតា

** ប័ណ្ណពណ៌លឿង: ប័ណ្ណសុខភាពកុមារា/កុមារី